**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ឆ្នាំង**

លេខ: ២.១២/ម៣ លស-៩

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

**កម្មវត្ថុ:** សំណើសុំអនុញ្ញាតគោរពអញ្ជើញ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុងកំពង់ឆ្នាំង** ចូលរួមជាគណ:អធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការពុទ្ធិកបឋមសិក្សាព្រះខេមរត្នេរភ្នំសន្ទូច និងសមិទ្ធផលនានា ក្នុងវត្តពលិសបព្វតារាម ហៅវត្តភ្នំសន្ទូច។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា រដ្ឋបាលខេត្តកំពង់ឆ្នាំងនឹងរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការពុទ្ធិកបឋមសិក្សាព្រះខេមរត្នេរភ្នំសន្ទូច និងសមិទ្ធផលនានា ក្នុងវត្តពលិសបព្វតារាម ហៅវត្តភ្នំសន្ទូច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៧:០០នាទីព្រឹក នៅវត្តពលិសបព្វតារាម ហៅវត្តភ្នំសន្ទូច ស្ថិតនៅភូមិសន្ទូច ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូមគោរពអញ្ជើញ **លោកជំទាវរដ្ឋលេខាធិការ** ចូលរួមជាគណ:អធិបតីក្នុងពិធីនេះដោយក្តីអនុគ្រោះ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃ ព្រ.ហ.១៤.រោច... ខែពិសាខ.... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ឆ្នាំង ថ្ងៃទី១៨...ខែឧសភា ឆ្នាំ២០២៣

**អភិបាលខេត្ត**

ស៊ុន_សុវណ្ណារិទ្ធិ

**បញ្ជាក់:-**

-សំលៀកបំពាក់: បុរសអាវធំ, នារីប្រពៃណី

-សូមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល